# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងសុខាភិបាល

# សេចក្តីសង្ខេប

# នៃក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម សម្រាប់ គម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា

**Executive Summary of the Environmental and Social Management Framework for Cambodia Covid19 Emergency Response Project**

## ២៩ មេសា ឆ្នាំ ២០២០

# សេចក្តីសង្ខេប

ក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម (**កគបស**)នេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់សកម្មភាពទាក់ទងបរិស្ថាន និងសង្គមដែលផ្តល់ថវិកាដោយក្រុមធនាគារពិភពលោកសម្រាប់ គម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ១៩នៅក្នុងប្រទេសកម្ពុជា។ ក្រសួងសុខាភិបាលគឺជាស្ថាប័នអនុវត្តគម្រោង។

គោលដៅចម្បងនៃក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម គឺត្រូវធានាឲ្យបាននូវការគោរពតាមពេញលេញនូវស្តង់ដារបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក នៃក្របខ័ណ្ឌបរិស្ថាននិងសង្គម (**កបស**) និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងនូវអំឡុងពេលនៃការអនុវត្តន៍គម្រោង។ គោលដៅជាក់លាក់នៃ **កគបស គឺ ក**) វាយតម្លៃហានិភ័យ និងផលប៉ះពាល់(ទាំងវិជ្ជមាន និងអវិជ្ជមាន) ដែលអាចកើតឡើយដោយសារគម្រោង ហើយនិងស្នើឡើងនូវវិធានការណ៍ ដែលអាចដោះស្រាយបានដោយមានប្រសិទ្ធិភាព **ខ**) បង្កើតនីតិវិធីច្បាស់លាស់សម្រាប់តាមដាន បរិស្ថាននិងសង្គម (screening) ការពិនិត្យឡើងវិញ ការឯកភាព និងការអនុវត្តន៍នូវសកម្មភាព **គ**) បញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវ និងការគូសបញ្ជាក់អំពីនីតិវិធីនៃការរាយការណ៍ចាំបាច់ សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យតាមដាននូវបញ្ហាឬកង្វល់អំពីបរិស្ថាននិង សង្គមដែលទាក់ទងទៅនិងសកម្មភាពនានា **ឃ**) កំណត់រកមើលការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដែលត្រូវការដើម្បីអនុវត្តក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គមឲ្យបានជោគជ័យ **ង**) លើកឡើងអំពីយន្តការសម្រាប់ការពិភាក្សាពិគ្រោះយោបល់ជាមួយសាធារណៈ និងការផ្សព្វផ្សាយ (disclosure) អំពីឯកសារនានារបស់គម្រោង ក៏ដូចជាដោះស្រាយអំពីបណ្តោះសារទុក្ខដែលអាចមាន ហើយនិង **ច**) បង្កើតឲ្យមានថវិកាដែលជាលក្ខ័ណតម្រូវសម្រាប់អនុវត្ត ក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម។ **កគបស** ក៏ផ្តល់នូវគោលការណ៍ និងដំណើរការជាក់លាក់ដើម្បីធានាថាក្រុមជនដែលមានការលំបាក ជនងាយរងគ្រោះ ឬក្រុមផ្សេងទៀត អាចទទួលបានផលប្រយោជន៍ពីគម្រោង។

# ការបរិយាយអំពីគម្រោង

សកម្មភាពរបស់គម្រោងត្រូវបានតាក់តែងឡើងដើម្បីគាំទ្រដល់ការបង្ខាំងទុក (containment) ក៏ដូចជាការកាត់បន្ថយនូវសកម្មភាពនានាដែលពាក់ព័ន្ធ ដែលរាជរដ្ឋាភិបាល

កម្ពុជា បានកំណត់នៅក្នុងផែនការមេនៃជំងឺកូវីដ១៩។ គម្រោងមានបួនសមាសធាតុដូចខាងក្រោម៖

**សមាសធាតុទី ១**: ការស្រាវជ្រាវ និងការគ្រប់គ្រងករណីជំងឺ (Case Detection and Management) (ដែលមានទឹកប្រាក់សរុប US$8.5 លានដុល្លារអាមេរិក)។ សកម្មភាពនៃសមាសធាតុនេះរួមមាន៖ បង្កើត និងបង្កើនសមត្ថភាពមន្ទីរពិសោធន៍ បន្ទប់ដាក់ឲ្យនៅដោយឡែក (isolation) និងមជ្ឈមណ្ឌលព្យាបាល (treatment centers) និងផ្គត់ផ្គង់សម្ភារនិងបរិក្ខារពេទ្យ គ្រឿងសង្ហារឹម និងតម្លើងបណ្តាញទំនាក់ទំនង (network installation)។ វិទ្យាស្ថានជាតិសុខភាពសាធារណៈនិងត្រូវបានបង្កើនសមត្ថភាព (upgraded) កសាងសមត្ថភាពធ្វើរោគវិនិច្ឆ័យរបស់មន្ទីរពិសោធន៍ទាំង២៥ នៅក្នុងមន្ទីរពេទ្យបង្អែករាជធានីខេត្ត ហើយនិងបង្កើតបន្ទប់ដាក់ឲ្យនៅដោយឡែក និងមជ្ឈមណ្ឌលព្យាបាលនៅក្នុងមន្ទីរពេទ្យបង្អែករាជធានីខេត្ត ទាំង២៥។

**សមាសធាតុទី២**: ផ្គត់ផ្គង់សម្ភារ និងបរិក្ខារពេទ្យ (Medical Supplies and Equipment) (ដែលមានទឹកប្រាក់សរុប US$6.5 លានដុល្លារអាមេរិក)។ សមាសធាតុនេះនិងផ្តល់ហិរញ្ញវត្ថុសម្រាប់ធ្វើលទ្ធកម្ម សម្ភារនិងបរិក្ខារពេទ្យដែលត្រូវការសម្រាប់សកម្មភាពដែលបានបរិយាយនៅក្នុងផែនការមេនៃជំងឺកូវីដ១៩ (COVID-19 Master Plan) ដែលរួមមានការបន្តធ្វើធុរៈកិច្ច (business continuity) នៃសេវាសារវ័ន្តដូចជា **(i)** ការគ្រប់គ្រងករណីជំងឺនិង **(ii)** ការទប់ស្កាត់និងការបង្ការការចម្លងរោគ។ ជាពិសេសទៅទៀត សម្ភារដែលបានធ្វើលទ្ធកម្មនិងរួមបញ្ចូលនូវ ឱសថនិងបរិក្ខារពេទ្យសម្រាប់ការគ្រប់គ្រងករណីជំងឺ និងការបង្ការការចម្លងរោគ។

**សមាសធាតុទី៣**: ការត្រៀមជាស្រេច ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល (ដែលមានទឹកប្រាក់សរុប US$3.5 លានដុល្លារអាមេរិក)។ សមាសធាតុនេះនិងផ្តល់ហិរញ្ញវត្ថុសម្រាប់ធ្វើសកម្មភាពដែលទាក់ទងទៅនិងការត្រៀមជាស្រេច ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល ដោយផ្អែកទៅតាមផ្នែកផ្សេងៗ និងសកម្មភាពនានារបស់ផែនការមេនៃជំងឺកូវីដ១៩។ សកម្មភាពទាំងនោះរួមមាន (1) ការសម្របសម្រួលនៅថ្នាក់ជាតិ ខេត្ត និងស្រុក (2) ការដាក់ឲ្យដំណើរការនូវមជ្ឈមណ្ឌលប្រតិបត្តិការឆ្លើយតបបន្ទាន់ (Emergency Operation Center-EOC) (រួមទាំងការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ និងការគាំទ្រសម្រាប់ការត្រៀមជាស្រេច (ដាក់ឲ្យដំណើរការនូវមជ្ឈមណ្ឌលប្រតិបត្តិការឆ្លើយតបបន្ទាន់ ការបណ្តុះបណ្តាល និងការអភិបាល) (3) ធនធានមនុស្សសម្រាប់អនុវត្ត ការអភិបាលគាំទ្រ និងការគាំទ្រនៅថ្នាក់ក្រោមជាតិ (4) ផ្តល់ហិរញ្ញវត្ថុសម្រាប់ថ្លៃប្រតិបត្តិ ដូចជា ការជួលយានយន្ត ប្រេង និងថ្លៃទាក់ទងទៅនិងការងាររដ្ឋ

បាលសម្រាប់ការការអភិបាលគាំទ្រ និងការត្រួតពិនិត្យតាមដាន (5) គាំទ្រការស្រាវជ្រាវ (screening) ប្រជាជនដែលចូលមកក្នុងប្រទេសនៅតាមច្រកទ្វារអន្តរជាតិ (ព្រលានយន្តហោះ ព្រំប្រទល់ឆ្លងកាត់ ។ល។) (6) ពង្រឹងប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (call/hotline centers) និង (7) ពង្រឹងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ១៩តាមសហាគមន៍ (community- and event-based surveillance)។ បន្ថែមពីនេះទៀត សមាសធាតុនេះនិងគាំទ្រដល់ (i) ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និង ការចូលរួមរបស់សហាគមន៍ (ii) ការវាយតម្លៃកត្តាហានិភ័យវប្បធម៌សង្គម និងឥរិយាបទ (iii) ការផលិតនូវយុទ្ធសាស្រ្តសម្រាប់ ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និង ការចូលរួមរបស់សហាគមន៍ ហើយនិងឯកសារបណ្តុះបណ្តាល (iv) ការផលិតនូវសម្ភារការប្រាស្រ័យទាក់ទង និង (vi) ការត្រួតពិនិត្យតាមដាន និងការបញ្ជេញទិន្នន័យជាភ័ស្តុតាង។

**សមាសធាតុទី៤**: ការអនុវត្តគម្រោង និងការត្រួតពិនិត្យតាមដាន (ដែលមានទឹកប្រាក់សរុប US$1.5 លានដុល្លារអាមេរិក)។ សកម្មភាពនៃសមាសធាតុនេះរួមមាន (1) ការគាំទ្រការធ្វើលទ្ធកម្ម ការគ្រប់គ្រងហាវិញ្ញវត្ថុ ការគាំពារបរិស្ថាន និងសង្គម ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ និងការរាយការណ៍ (2) ការជ្រើសរើសបុគ្គលិក និងការបណ្តុះបណ្តាលបុគ្គលិកស្ថាប័នអនុវត្តគម្រោង និងអ្នកជំនួយការបច្ចេកទេស (consultants) និង (3) ថវិកាសម្រាប់ប្រតិបត្តិ (operating costs)។

## ស្តង់ដារបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោកដែលអាចអនុវត្តបាន

ហានិភ័យបរិស្ថាន និងសង្គមត្រូវបានចំណាត់ថ្នាក់ជា " Substantial " សម្រាប់គម្រោងនេះ។ ក្នុងចំណោមស្តង់ដារបរិស្ថាន និងសង្គម (**សបស**) (Social Standards (ESS) ទាំង១០ ក្នុងនោះ **សបស** ចំនួនប្រាំមួយ នៃក្របខ័ណ្ឌបរិស្ថាននិងសង្គមរបស់ធនាគារពិភពលោកត្រូវបានត្រួតពិនិត្យ ហើយពាក់ព័ន្ធជាមួយគម្រោង ដូចជា:

- **សបសទី១**: ការវាយតម្លៃនិងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ដល់បរិស្ថាន និងសង្គម
- **សបសទី២**: លក្ខខណ្ឌការងារ និងពលកម្ម
- **សបសទី៣**: ធនធានគ្រប់គ្រាន់ និង ការគ្រប់គ្រង និងការការពារនៃការបំពុលបរិស្ថាន
- **សបសទី៤**: សុវត្ថិភាព និងសុខភាពសហាគមន៍
- **សបសទី៧**: ជនជាតិដើមភាគតិច/សហាគមន៍ជនជាតិអាហ្វ្រិកនៅអនុតំបន់សាហារ៉ា
- **សបសទី១០**: ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌ជាសាធារណៈ

ក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គមក៏បានពិចារណាអំពីលក្ខ័ណតម្រូវ ក៏ដូចជាការអនុវត្តនូវពិធីសារអន្តរជាតិសម្រាប់ការទប់ស្កាត់នូវជំងឺឆ្លង និងការគ្រប់គ្រងសំណល់វេជ្ជសាស្រ្ត។

សេចក្តីណែនាំរបស់ក្រុមធនាគារពិភពលោក អំពីសុវត្ថិភាព សុខភាព និងបរិស្ថាន និងត្រូវអនុវត្ត ដូចគ្នាជាមួយនិងសេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោកអំពីជំងឺកូវីដ១៩ (សូមមើលឧបសម្ព័ន្ធឯកសារយោង) និងផ្តោតទៅលើ "មូលដ្ឋានសុខាភិបាល" "ការគ្រប់គ្រងសំណល់" "ការគ្រប់គ្រងសម្ភារគ្រោះថ្នាក់" និង "ការសាងសង់ និង ការរុះរើចេញ "។

## ហានិភ័យបរិស្ថាន និងសង្គម និងផលប៉ះពាល់

គម្រោងនេះនិងត្រូវអនុវត្តនៅទូទាំងប្រទេស ប៉ុន្តែមិនមានការសាងសង់ថ្មីទេ គឺមានតែការជួសជុលតូច ឬក៏ពង្រីក (renovation or rehabilitation) នូវមន្ទីរពិសោធន៍ដែលស្ថិតនៅក្នុងមូលដ្ឋានសុខាភិបាលដែលមានស្រាប់។ គម្រោងនេះផ្តល់ហិរញ្ញវត្ថុសម្រាប់តែការជួសជុលនូវអាគារដែលមានស្រាប់ មិនមានតម្រូវការនូវការកាន់កាប់ដីធ្លីទេ ឬក៏មានផលប៉ះពាល់រំពឹងទុកដែលអាចឲ្យមានការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្តឡើយ៕ ជាលទ្ធផលគឺមិនមានផលប៉ះពាល់ ឬក៏ហានិភ័យដល់ធម្មជាតិសត្វ រុក្ខជាតិ តំបន់ការពារ ឬក៏ទីកន្លែងវប្បធម៌ឡើយ។ ទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការនៃការត្រៀមជាស្រេច និងការឆ្លើយតបទៅនិងជំងឺកូវីដ១៩ ដោយប្រើមន្ទីរពិសោធន៍ (សម្ភារ រេអាទីវ សារធាតុគីមី) ក៏ដូចជាបន្ទប់ចត្តាឡីស័ក បន្ទប់ដាក់អ្នកជំងឺឲ្យនៅដោយឡែក អាចមានផលប៉ះពាល់ធំដល់បរិស្ថាន និងសង្គម ដែលទាក់ទងទៅនិងការទុកដាក់សំណល់វេជ្ជសាស្រ្ត ហើយនិងការឆ្លងវីរុសកូវីដ បើពិធីសារនៃការបង្ការរោគមិនត្រូវបានអនុវត្តតាម។

លើសពីនេះទៀត ការជួសជុលកែលម្អ (rehabilitation/upgrade/renovation) នូវអាគារមូលដ្ឋានសុខាភិបាលអាចឲ្យមានផលរំខានខ្លះដូចជា មានធូលី សម្លេង រំញ័រ សំណល់អាគារ សំណល់ទឹកបង្ហូរ ការស្ទះចរាចរណ៍ បញ្ហាសុវត្ថិភាព ស្ថានភាពអនាម័យទូទៅ និងរាងកាយរបស់កម្មករសំណង់ ហើយនិងការរំខានដល់អ្នកជិតខាង និងបរិស្ថាន។ ផលប៉ះពាល់នេះត្រូវបានវាយតម្លៃថាវាកើតមានតែនៅកន្លែងមួយជាក់លាក់តែប៉ុណ្ណោះ មានរយៈពេលខ្លី ហើយអាចត្រូវបានកាត់បន្ថយដោយការរៀបចំ និងការអនុវត្តនូវការសាងសង់បានល្អ។ ចំពោះគម្រោងប្រភេទនេះ ដែលសំដៅដល់កម្រិតទី២នៃអនុគម្រោង (Tier 2 subproject) និងត្រូវប្រើបញ្ជីផ្ទៀងផ្ទាត់គ្រប់គ្រងបរិស្ថានដើម្បីកាត់បន្ថយផលប៉ះពាល់ ពីការជួសជុលកែលម្អអាគារ

នេះ។

សំណល់វេជ្ជសាស្ត្រ និងសំណល់ជាតិគីមី (រួមមានទឹក សម្ភារមានមេរោគ ជាដើម) ដែលចេញពីមន្ទីរពិសោធន៍ បន្ទប់ចត្តាឡីស័ក និងប៉ុស្តិ៍ស្រាវជ្រាវ (ដែលមានផ្តល់ឱសថ សម្ភារ និងបរិក្ខារពេទ្យ) អាចមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន និងសុខភាពមនុស្ស ជាពិសេសលទ្ធភាពដែលអាចចម្លងជំងឺកូវីដ១៩។

មន្ទីរពិសោធន៍ និងមូលដ្ឋានសុខាភិបាលនីមួយៗនិងត្រូវអនុវត្តតាមលក្ខ័ណតម្រូវរបស់ក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម ហើយនិងវិធានការណ៍កាត់បន្ថយដែលបានគូសបញ្ជាក់ ដោយអនុវត្តស្របតាមសេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោកអំពីជំងឺកូវីដ និងការអនុវត្តមានប្រសិទ្ធិភាពផ្សេងទៀតរបស់អន្តរជាតិ ហើយនិងរៀបចំ អនុវត្តតាមផែនការគ្រប់គ្រងសំណល់ និងការបង្ការការចម្លងរោគ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់នេះ។ សកម្មភាពភាគច្រើនដែលគាំទ្រដោយគម្រោង និងត្រូវបានអនុវត្តដោយបុគ្គលិកសុខាភិបាល បុគ្គលិកមន្ទីរពិសោធន៍រួមមាន បុគ្គលិកមិនមែនជាគ្រូពេទ្យ (ដូចជាអ្នកបោសសម្អាត និងអ្នកបើកបរ) ហើយនិងទីប្រឹក្សាជំនួយការ និងអ្នកមៅការ។ ហានិភ័យចម្បងចំពោះអ្នកបំពេញការងារទាំងនេះគឺការឆ្លងជំងឺកូវីដ១៩ (ឬក៏ការឆ្លងជំងឺផ្សេងទៀត)។ នីតិវិធីនៃការគ្រប់គ្រងពលកម្មនៅក្នុង ក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម គឺបានគ្របដណ្តប់ទៅលើហានិភ័យទាំងនេះដែលទាក់ទងទៅនិងការចូលទៅក្នុងមូលដ្ឋានសុខាភិបាល នីតិវិធីសម្រាប់ការពារកម្មករដែលទាក់ទងទៅនិងការប្រុងប្រយ័ត្នចំពោះការបង្ការរោគ ការផ្តល់នូវការបណ្តុះបណ្តាលភ្លាមៗ និងបណ្តុះបណ្តាលបន្ត ដល់គ្រប់កម្មករគ្រប់ប្រភេទ ការបណ្តុះបណ្តាលអំពីការប្រើឧបករណ៍ការពារខ្លួន (PPE) ហើយនិងធានាឲ្យបាននូវការការពារនៅនឹងកន្លែងអំពីសុវត្ថិភាព និងសុខភាពការងារ (Occupational Health and Safety)។ គម្រោងក៏និងបញ្ចូលជាទៀងទាត់នូវសេចក្តីណែនាំថ្មីៗ របស់អង្គការសុខភាពពិភពលោក ដើម្បីឆ្លើយតបទៅនិងជំងឺកូវីដ១៩នេះ។ ប្រតិបត្តិការនៃការធ្វើចត្តាឡីស័ក និងការដាក់អ្នកជំងឺឲ្យនៅដោយឡែក ត្រូវអនុវត្តនៅក្នុងលក្ខណៈដែល បុគ្គលិកសុខាភិបាល អ្នកជំងឺ ហើយនិងសាធារណៈជន ត្រូវអនុវត្តតាម ហើយអ្នកជំងឺត្រូវបានព្យាលបាលទៅតាមការអនុវត្តដ៏ល្អជាលក្ខណៈអន្តរជាតិ ដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោកក្នុងការឆ្លើយតបទៅនិងជំងឺកូវីដ១៩។ ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ ក៏និងត្រូវធានាឲ្យមានការចូលរួមយ៉ាងទូលាយពីសហគមន៍ ដើម្បីផ្សព្វផ្សាយព័ត៌មាន ដែលទាកើទងទៅនិងសុវត្ថិភាព និងសុខភាពសហគមន៍ ជាពិសេសអំពីគម្លាតសង្គម ក្រុមជនងាយរងគ្រោះខ្ពស់តាមលក្ខណៈប្រជាសាស្ត្រ ការធ្វើចត្តាឡីស័កខ្លួន

ឯង ហើយនិង ការធ្វើចត្តាឡីស័កដោយបង្ខំ។ គម្រោងនិងខិតខំធានាឲ្យបានថាសម្ភារសម្រាប់ការប្រាស្រ័យទាក់ទងត្រូវបានផលិតឡើង នៅក្នុងលក្ខណៈដែលអាចទទួលយកបាន ហើយសម្ភារនោះត្រូវបានប្រើដោយប្រជាជនគ្រប់រូប គ្រប់ក្រុមទាំងអស់ ជាពិសេសក្រុមជនងាយរងគ្រោះខ្ពស់។

ហានិភ័យផ្សេងៗទៀតពីគម្រោងរួមមាន ការកេងប្រវ័ញ្ចនិងការបំពានផ្លូវភេទ (Sexual Exploitation and Abuse (SEA) អំពើហឹង្សាលើស្ត្រី និងអំពើហឹង្សាលើកុមារ និងត្រូវបានដោះស្រាយនៅក្នុងវិធានការណ៍កាត់បន្ថយដែលមាននៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម នីតិវិធីនៃការគ្រប់គ្រងពលកម្ម ហើយនិងក្រមសីលធម៌ (Codes of Conduct)។ ការពិចារណាអំពីយេនឌ័រក៏ជាផ្នែកមួយនៃសមាសធាតុរបស់គម្រោងដែរ ជាពិសេសកម្លាំងធនធាននៃបុគ្គសុខាភិបាលនៅក្នុងប្រទេសជាស្ត្រី។វិធានការណ៍កាត់បន្ថយហានិភ័យទាំងអស់នេះ ហើយនិងហានិភ័យផ្សេងទៀតគឺមាននៅក្នុង ក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម។

## ដំណើរការស្រាវជ្រាវបរិស្ថាន និងសង្គម (Screening Process)

គោលបំណងនៃការស្រាវជ្រាវគឺ ១) កំណត់រកមើលថាតើសកម្មភាពណាខ្លះដែលអាចមានផលប៉ះពាល់ និងហានិភ័យអវិជ្ជមានដល់បរិស្ថាន និងសង្គម ២) កំណត់រកមើលវិធានការណ៍កាត់បន្ថយសមស្របចំពោះសកម្មភាពដែលបណ្តាលឲ្យមានហានិភ័យ ឬផលប៉ះពាល់អវិជ្ជមាន ៣) ដាក់បញ្ចូលនូវវិធានការណ៍កាត់បន្ថយទៅក្នុងការអនុវត្តនៃសកម្មភាព ៤) ពិនិត្យមើលឡើងវិញ និងឯកភាពលើផែនការគ្រប់គ្រង និង ៥) តាមដានការអនុវត្តនូវផែនការគ្រប់គ្រងចំពោះសកម្មភាពដែលតម្រូវឲ្យមានការប្រុងប្រយ័ត្ន (due diligence) ទៅលើបរិស្ថាន និងសង្គម។

## ការត្រួតពិនិត្យតាមដាន ការអភិបាលនិង ការរាយការណ៍

នាយកដ្ឋាន/ស្ថាប័នអនុវត្តគម្រោងនិងរៀបចំ និងផ្ញើទៅធនាគារពិភពលោកជាទៀតទាត់នូវរបាយការណ៍ត្រួតពិនិត្យតាមដានអំពីការអនុវត្តនូវសុវត្ថិភាព សុខភាពបរិស្ថាន និងសង្គមរបស់គម្រោង ដែលរួមមាន សកម្មភាពចូលរួមរបស់អ្នកពាក់ព័ន្ធ និងកំណត់ត្រានៃបណ្តឹងសារទុក្ខ។ គណៈកម្មការគ្រប់គ្រងមូលដ្ឋានសុខាភិបាល និងទទួលខុសត្រូវលើការចុះអភិបាលជារៀងរាល់ថ្ងៃអំពីការអនុវត្តន៍នូវវិធានការណ៍កាត់បន្ថយផលប៉ះពាល់បរិស្ថាន និង

សង្គម។ ក្រុមអភិបាលការងារសំណង់និងបញ្ចូលនូវស្ថានភាពនៃការអនុវត្តន៍នូវផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (Environmental and Social Management Plan) និងឬក្រមនៃការអនុវត្តន៍បរិស្ថាន (Environmental Codes of Conduct (ECOP) ដែលពាក់ព័ន្ធចូលទៅក្នុងរបាយការណ៍ត្រួតពិនិត្យតាមដានប្រចាំខែនេះ។

នាយកដ្ឋានការពារសុខភាពនិងទទួលខុសត្រូវចំពោះការត្រួតពិនិត្យតាមដានក្នុងការអនុវត្តន៍នូវក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម (**កគបស**) និង ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ហើយនិងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តន៍រៀងរាល់៦ខែម្តង។ លក្ខ័ណតម្រូវនៃការរាយការណ៍នេះនិងត្រូវបានបញ្ចូលទៅក្នុងសេចក្តីណែនាំប្រតិបត្តិរបស់គម្រោង (Operation Manual)។

## ការរៀបចំនៃការអនុវត្តន៍គម្រោង និងការទទួលខុសត្រូវ

ផែនការជាតិដើម្បីត្រៀមឆ្លើយតបទៅនិងជំងឺកូវីដក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងឆ្នាំ២០១៩។ ក្រសួងសុខាភិបាលដែលជាស្ថាប័នដឹកនាំការងារបច្ចេកទេសទទួលខុសត្រូវចំពោះការរៀបចំផែនការ និងត្រួតពិនិត្យមើលនូវការឆ្លើយតបរបស់ផ្នែកសុខាភិបាល។ នាយកដ្ឋានប្រយុទ្ធជំងឺឆ្លងនៃក្រសួងសុខាភិបាល ដើរតួជានាយកដ្ឋានសម្របសម្រួលនៅក្នុងឆ្លើយតបទៅនិងជំងឺកូវីដ១៩ ហើយប្រធាននាយកដ្ឋានប្រយុទ្ធជំងឺឆ្លង គឺជាអ្នកនាំពាក្យថ្នាក់ជាតិ។ បន្ថែមពីលើការរៀបចំនៃការអនុវត្តន៍គម្រោងនេះ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ត្រូវបានបង្កើតឡើងនាថ្ងៃទី ១០ខែមីនា ឆ្នាំ ២០២០ ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាលជាប្រធាន។ គណៈកម្មការអន្តរក្រសួងនេះមានសមាជិក ១៥រូបដែលមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។ គណៈកម្មការនេះមានភារកិច្ចដូចតទៅ:

- ១) រៀបចំផែនការឆ្លើយតបជំងឺកូវីដ១៩ទៅតាមការវិវត្តន៍នៃការរីករាលដាលនៃវីរុស
- ២) អនុវត្តសកម្មភាពតាមផែនការដែលអនុម័តដោយប្រមុខរាជរដ្ឋាភិបាល
- ៣) តាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនវុត្តនៃការប្រយុទ្ធនិងជំងឺកូវីដ១៩
- ៤) លើកទិសដៅប្រតិបត្តិជាយថាហេតុតាមស្ថានភាពជាក់ស្តែងនៃការរាតត្បាតជំងឺកូវីដ១៩
- ៥) គោរពរាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាលអំពីវិវត្តន៍នៃជំងឺកូវីដ១៩
- ៦) ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

## ការកសាងសមត្ថភាព

គម្រោងនិងផ្តល់ថវិកា ការបណ្តុះបណ្តាល និងកសាងសមត្ថភាពដើម្បីគ្រប់គ្រងហានិភ័យដែលទាក់ទងទៅនិងជំងឺកូវីដ១៩ រួមមាន ការធ្វើរោគវិនិច្ឆ័យ ចត្តាឡីស័ក បន្ទប់ដាក់អ្នកជំងឺនៅដោយឡែក សម្រាប់ព្យាបាលអ្នកជំងឺកូវីដ១៩។ វិធានការណ៍ពិសេសសម្រាប់ការប្រាស្រ័យទាក់ទងជាមួយសាធារណៈ និងការដោះស្រាយកង្វល់របស់សង្គមអំពីបញ្ហាជំងឺកូវីដ១៩ក៏បានដាក់បញ្ចូលផងដែរ។ គំនិតផ្តួចផ្តើមសំខាន់នេះនិងត្រូវផ្អែកទៅលើការអនុវត្តន៍ឆ្លើយតបល្អបំផុតតាមលក្ខណៈអន្តរជាតិហើយស្របតាមសេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោក។

## ការពិគ្រោះពិភាក្សា និងការចូលរួមរបស់អ្នកពាក់ព័ន្ធ

គម្រោងបានរៀបចំ និងបានពិភាក្សាអំពីផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលបានកំណត់អំពីកម្មវិធីសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធ រួមមានការផ្សព្វផ្សាយជាសាធារណៈ និងការពិគ្រោះពិភាក្សា នៅពេញរយៈពេលនៃការអនុវត្តន៍គម្រោង។ ផែនការនេះក៏បានគូសបញ្ជាក់ផងដែរអំពីយុទ្ធសាស្រ្តសម្រាប់ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធគម្រោង ហើយនិងផ្តលជូននូវយន្តការដល់ពួកគាត់ដើម្បីលកើឡើងពីកង្វល់នានា ផ្តល់ព័ត៌មានត្រឡប់ ឬក៏ប្តឹងអំពីគម្រោង។ ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធគឺជាផែនការដែលអាចធ្វើបច្ចុប្បន្នភាពបាន (living document) ដែលមានគោលដៅ:

- កំណត់អត្តសញ្ញាណនៃអ្នកពាក់ព័ន្ធទាំងអស់ រួមមានអាទិភាព ហើយនិងកង្វល់របស់ពួកគេ និងដើម្បីធានាបានថាគម្រោងមានវិធីសម្រាប់បញ្ចូល និងដោះស្រាយ កង្វល់ទាំងនោះ
- កំណត់រកយុទ្ធសាស្រ្តសម្រាប់ចែករំលែកព័ត៌មានដល់អ្នកពាក់ព័ន្ធ ហើយដែលពួកគាត់អាចទទួលបាន
- បញ្ជាក់ច្បាស់អំពីនីតិវិធី និងវិធីសាស្រ្តសម្រាប់ការពិគ្រោះពិភាក្សាជាមួយអ្នកពាក់ព័ន្ធទុកដាក់ឯកសារនៃវិធីដំណើរការ និងយុទ្ធសាស្រ្តសម្រាប់ផ្តល់ព័ត៌មានត្រឡប់
- បង្កើតយន្តការឆ្លើយតបទៅនិងបណ្តឹងសារទុក្ខដែលអ្នកពាក់ព័ន្ធអាចប្រើបាន ហើយសមស្របទៅតាមវប្បធម៌របស់ពួកគេ
- បង្កើតយុទ្ធសាស្រ្តសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធ នៅក្នុងការត្រួតពិនិត្យតាមដានផលប៉ះពាល់ដែលបណ្តាលមកពីគម្រោង។

## យន្តការដោះស្រាយបណ្តឹងសារទុក្ខ (Grievance Redress Mechanism)

យន្តការដោះស្រាយបណ្តឹងសារទុក្ខ គឺជាផ្នែកមួយនៃក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាន និងសង្គម និង ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធរបស់គម្រោង ហើយនិងត្រូវបានបង្កើតឡើងដើម្បីដោះស្រាយរាល់បណ្តឹងសារទុក្ខ ការមិនសុខចិត្តឲ្យបានទាន់ពេលវេលា ព្រមទាំងមានប្រសិទ្ធិភាព និងប្រសិទ្ធិភាពតម្លៃ។ រាល់បណ្តឹងសារទុក្ខទាក់ទងទៅនិងគម្រោង អាចបញ្ជូនទៅដើម្បីពិនិត្យមើលផលប៉ះពាល់អវិជ្ជមាន (detrimental impact) ទៅលើសហាគមន៍ បរិស្ថាន ឬគុណភាពនៃជីវិតរស់នៅរបស់ពួកគាត់។ អ្នកពាក់ព័ន្ធក៏អាចធ្វើសំណូមពរ ឬក៏ផ្តល់មតិផងដែរ។ យន្តការដោះស្រាយបណ្តឹងសារទុក្ខ ផ្តល់នូវវិធានការណ៍ដោះស្រាយរាល់វិវាទណាមួយផ្តល់នូវសកម្មភាពដោះស្រាយសមស្រប ហើយចៀសវាងនូវតម្រូវការដោះស្រាយតាមផ្លូវតុលាការ (judicial proceedings)។ បណ្តឹងសារទុក្ខនិងត្រូវបានដោះស្រាយនៅថ្នាក់មន្ទីរពេទ្យបង្អែករាជធានី ខេត្តនីមួយៗ និងនៅថ្នាក់ជាតិដោយ គណៈកម្មការដោះស្រាយបណ្តឹងសារទុក្ខ (Grievance Redress Committee) ដែលនិងត្រូវបង្កើតឡើងដោយក្រសួងសុខាភិបាល រួមមានប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍។

## ថវិកា

ថវិកាសម្រាប់អនុវត្តក្របខ័ណ្ឌនៃការគ្រប់គ្រងបរិស្ថាននិងសង្គម ត្រូវបានបែងចែកសម្រាប់ ការបណ្តុះបណ្តាល ការបង្កើតវិធានការណ៍បង្ការបរិស្ថាន និងសង្គម ហើយនិងឧបករណ៍មួយចំនួនទៀត។ ថវិកាអាចប្រើសម្រាប់ជួលជំនួយការ ដើម្បីរៀបចំផែនការគ្រប់គ្រងបរិស្ថាននៅទីកន្លែងជាក់លាក់ (ESS site specific EMP) ទៅតាមស្តង់ដារបរិស្ថាន និងសង្គម ហើយនិងធ្វើរបាយការណ៍ទាក់ទងទៅនិងបរិស្ថាន និងសង្គម។ ថ្លៃសម្រាប់ធ្វើដំណើរដើម្បីចុះត្រួតពិនិត្យតាមដាន និងធ្វើការបណ្តុះបណ្តាលក៏ដូចជាការចូលរួម ជាមួយបេសកកម្មអភិបាលរបស់ធនាគារពិភពលោក ក៏ត្រូវបានកំណត់។ ថវិការំពឹងទុកសម្រាប់អនុវត្តការងារទាំងនេះត្រូវបានប៉ាន់ស្មានប្រមាណជា $238,000 ដុល្លាអាមេរិក។ គួរកត់សម្គាល់ផងដែរថា ធនាគារពិភពលោកក៏បានដាក់ឲ្យដំណើរការនូវ សមាសធាតុឆ្លើយតបបន្ទាន់ទៅនិងជំងឺកូវីដ១៩ (COVID-19 CERC: Contingency Emergency Response Component) នៅក្នុងគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល ដែលមានសកម្មភាពអនុវត្តស្របគ្នា ហើយថវិកាដែលប៉ាន់ស្មាននៅទីនេះអាចពិនិត្យមើលជាមួយសកម្មភាពដែលកំពុងតែដំណើរការ ដោយក្រសួងសុខាភិបាល ដើម្បីធានាបាននូវការសន្សំសំចៃថវិកា (costs savings)។